**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Dec-2012, 15:53
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃ ១២ ខែធ្នូ ឆ្នាំ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សំណើបន្ថែមរបស់ អៀង សារី សុំឲ្យអ្នកជំនាញដែលមានសមត្ថភាពធ្វើការពិនិត្យវេជ្ជសាស្ត្រប្រចាំថ្ងៃ ទាក់ទិននឹងសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយក្នុងការការពារខ្លួនគាត់ផ្ទាល់**
**ឬម៉្យាងទៀត**
**សំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក ធ្វើការអង្កេតជាក់លាក់ ទាក់ទិននឹងសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយក្នុងការការពារខ្លួនគាត់ផ្ទាល់**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី អៀង សារី**
អាង ឧត្តម
Michael G. KARNAVAS

**ចម្លងជូន៖**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម **និល ណុន**
ចៅក្រម **យ៉ា ឧត្តារា**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **ធូ មន្នី**
ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**
ជា លាង
Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**
**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) សូមដាក់បន្ថែមទៅនឹងសំណើដោយផ្ទាល់មាត់ដែលធ្វើឡើងជាបន្តបន្ទាប់ ដោយសហមេធាវីរបស់គាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យអ្នកជំនាញធ្វើការពិនិត្យវេជ្ជសាស្ត្រជារៀងរាល់ថ្ងៃ ដើម្បីវាយតម្លៃអំពីសមត្ថភាពរបស់គាត់ក្នុងការជួយដល់ការការពារ ដោយផ្ទាល់ខ្លួនរបស់គាត់។ សំណើនេះមានសារៈសំខាន់ណាស់ ពីព្រោះវេជ្ជបណ្ឌិត អ.វ.ត.ក បានបង្ហាញថា ពួកគាត់ពុំមានជំនាញដែលចាំបាច់សម្រាប់ជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើ លោក អៀង សារី មានសមត្ថភាពចាំបាច់ដែរ ឬយ៉ាងណានោះឡើយ។ ក្នុងកម្រិតអប្បបរមា មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ដល់វេជ្ជបណ្ឌិត អ.វ.ត.ក ធ្វើការសាកសួរ និងអង្កេតឲ្យបានជាក់លាក់ជារៀងរាល់ថ្ងៃ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃអំពីសមត្ថភាពប្រចាំថ្ងៃរបស់ អៀង សារី ដើម្បីជួយដល់ការការពារខ្លួនរបស់គាត់។

1. នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ លោក អាង ឧត្តម សហមេធាវីជាតិរបស់លោក អៀង សារី បានស្នើឲ្យមានការតែងតាំងអ្នកជំនាញមួយរូបជាប្រចាំរាល់ថ្ងៃ ដើម្បីជួយវាយតម្លៃសមត្ថភាពរបស់ អៀង សារី ក្នុងការចូលរួមការការពារខ្លួនរបស់គាត់[1]។ សំណើសុំអ្នកជំនាញបន្ថែមនេះ គឺជាសំណើមួយ ដែលកំពុងតែដំណើរការ[2] ពីព្រោះមេធាវីការពារក្តីព្រួយបារម្ភថា ជំងឺផ្លូវកាយរបស់លោក អៀង សារី ប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី ដូចគ្នាក្នុងករណីដែលជនជាប់ចោទអាចមានសុខភាពរឹងប៉ឹងដែរ។ លោក អាង ឧត្តម មិនបានអះអាង ហើយតាមពិត មេធាវីការពារក្តីមិនដែលបានអះអាងឡើយថា លោក អៀង សារី កំពុងតែមានវិកលភាព ឬជំងឺផ្លូវចិត្ត ដែលធ្វើឲ្យគាត់មិនអាចចូលរួមក្នុងការការពារខ្លួនគាត់ប្រកបដោយប្រសិទ្ធភាពនោះឡើយ[3]។

2. ចាប់តាំងពីអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា លោក អៀង សារី មានសម្បទាទាំង

---

[1] សេចក្តីព្រាងប្រតិចារឹក ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៣-៤។

[2] សូមមើល ឧទាហរណ៍ ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E1/143.1 ទំព័រ ៧-១១។

[3] សំណើរបស់ អៀង សារី សុំឲ្យមានការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលយល់ឃើញថាគាត់មានសម្បទាក្នុងការចូលរួមសវនាការ និងបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញបន្ថែមមួយរូបដើម្បីជួយក្នុងការកំណត់អំពីសម្បទា កថាខណ្ឌ ៣២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៣៧-៣៨។

ផ្លូវកាយ និងផ្លូវចិត្តដើម្បីចូលរួមក្នុងសវនាការ[4] ដែលនេះជាបញ្ហាដែលមេធាវីការពារក្ដីជំទាស់នោះ[5] លោក អៀង សារី ស្ថិតនៅក្នុងបន្ទប់រង់ចាំសម្រាប់ផ្នែកសំខាន់ៗនៃថ្ងៃសវនាការនីមួយៗ។ គាត់ពុំមានសមត្ថភាពក្នុងការតាមដានកិច្ចដំណើរការនីតិវិធីឡើយ មិនមែនគាត់មិនមានឆន្ទៈក្នុងការតាមដានកិច្ចដំណើរការនីតិវិធីនោះទេ។ មេធាវីការពារក្ដីជំទាស់យ៉ាងដាច់ខាតទៅនឹងសញ្ញាណជារួមរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា លោក អៀង សារី កំពុងតែដេកក្នុងអំឡុងកិច្ចដំណើរការនីតិវិធី ពីព្រោះគាត់ធុញទ្រាន់ ឬក៏មិនចាប់អារម្មណ៍នោះ[6]។ ពុំមានចៅក្រមណាម្នាក់ជាវេជ្ជបណ្ឌិតឡើយ ហើយពុំមានចៅក្រមណាម្នាក់បានធ្វើការអង្កេតលើស្ថានភាពរបស់លោក អៀង សារី ឡើយ ចាប់តាំងពីគាត់ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា លោក អៀង សារី មិនត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការទេ (ទីកន្លែងដែលគាត់អាចត្រូវបានត្រួតពិនិត្យជាប្រចាំ) ប៉ុន្តែត្រូវតែស្ថិតនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោមសាលសវនាការ (ទីកន្លែងដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនឲ្យថតវីដេអូគាត់)។

3. ដើម្បីត្រួតពិនិត្យលោក អៀង សារី មេធាវីការពារក្ដីបានចាត់តាំងអ្នកគ្រប់គ្រងសំណុំរឿង លោក សូ មូស្សេទ្ទី (ដែលជាសមាជិកនៃគណៈមេធាវីកម្ពុជា និងមានបទពិសោធន៍ផ្នែកច្បាប់គ្រប់គ្រាន់) ឲ្យស្ថិតនៅក្នុងបន្ទប់រង់ចាំដើម្បីធ្វើការអង្កេត និងធ្វើកំណត់ហេតុអង្កេតរបស់គាត់ ដោយត្រូវធ្វើរបាយការណ៍ប្រចាំថ្ងៃ និងប្រសិនបើចាំបាច់ ត្រូវចូលរួមជាមួយវេជ្ជបណ្ឌិត។ ជាពិសេស លោក សូ មូស្សេទ្ទី បានធ្វើកំណត់ហេតុថា វេជ្ជបណ្ឌិត លឹម ស៊ីរុតថា បាននិយាយថា គាត់មិនអាចធ្វើការវាយតម្លៃចំពោះសមត្ថភាពផ្លូវចិត្តរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី

---

[4] សេចក្ដីសម្រេចស្ដីពីសម្បទារបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E238/9។

[5] សូមមើល សំណើរបស់ អៀង សារី សុំឲ្យមានការពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលយល់ឃើញថាគាត់មានសម្បទាក្នុងការចូលរួមសវនាការ និងបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញបន្ថែមមួយរូបដើម្បីជួយ ក្នុងការកំណត់អំពីសម្បទា ចុះ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ឯកសារលេខ E238/11។

[6] សូមមើល ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/148.1 ទំព័រ ៣៧-៣៨ ។

បានឡើយ ពីព្រោះគាត់ពុំមែនជាវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យាឡើយ[7]។ នៅថ្ងៃបន្ទាប់ វេជ្ជ បណ្ឌិត គីម សមសាន្ត ក៏បានប្រាប់លោក ស្វ មូស្សេទ្ធី ថា គាត់មិនអាចធ្វើការវាយតម្លៃអំពីសមត្ថភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីឡើយ[8]។

4. វេជ្ជបណ្ឌិតរបស់ អ.វ.ត.ក មានសមត្ថភាពក្នុងការវាស់សម្ពាធឈាម និងជីពចររបស់លោក អៀង សារី និងត្រួតពិនិត្យសុខភាពទូទៅរបស់គាត់។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការទទួលស្គាល់របស់ពួកគាត់ផ្ទាល់ដែលត្រូវបានធ្វើកំណត់ហេតុត្រឹមត្រូវ ពួកគាត់ពុំមានសមត្ថភាពក្នុងការសម្រេចថាតើលោក អៀង សារី ពិតជាអាចតាមដានកិច្ចដំណើរការនីតិវិធីនៅថ្ងៃសវនាការនីមួយៗដែលពួកគាត់បានត្រួតពិនិត្យគាត់ ឬយ៉ាងណានោះឡើយ។

5. ដោយយោងទៅលើមូលហេតុទាំងអស់នេះហើយ ទើបក្រុមមេធាវីការពារក្តីសូមស្នើដាក់បំពេញបន្ថែមទៅក្នុងសារណាផ្ទាល់មាត់របស់ខ្លួនថា ក្រុមវេជ្ជបណ្ឌិតដែលបានចាត់តាំងឲ្យពិនិត្យតាមដានសុខភាពលោក អៀង សារី សព្វថ្ងៃ មិនបានផ្តល់ព័ត៌មានលម្អិតចាំបាច់សម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការវាយតម្លៃមួយឲ្យបានត្រឹមត្រូវអំពីសមត្ថភាពរបស់លោក អៀង សារី ដើម្បីតាមដានដំណើរការនីតិវិធីពេញមួយថ្ងៃៗនោះទេ ហើយតាមការទទួលស្គាល់ផ្ទាល់របស់ខ្លួន គឺវេជ្ជបណ្ឌិតទាំងនេះមិនអាចធ្វើការវាយតម្លៃដោយខ្លួនឯងបានទេ។ ក្រុមមេធាវីការពារក្តីសូមស្នើឲ្យក្រុមវេជ្ជបណ្ឌិតដែលមានជំនាញគ្រប់គ្រាន់ ពិនិត្យសុខភាពរបស់គាត់ជាប្រចាំថ្ងៃ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃទៅលើសមត្ថភាពរបស់លោក អៀង សារី ដើម្បីតាមដានដំណើរការនីតិវិធី។ នេះជាបញ្ហាដែលព្រះរាជអាជ្ញាជាន់ខ្ពស់ Keith Raynor បានបញ្ជាក់ថា ចាំបាច់ និងសមហេតុផលដើម្បី៖ **(ក)** ធានាដល់សិទ្ធិរបស់លោក អៀង សារី **(ខ)** កាត់បន្ថយការរារាំងណាមួយដល់ដំណើរការនីតិវិធីឲ្យស្ថិតក្នុងកម្រិតអប្បបរមា[9]។

---

[7] *សូមមើល* សេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តីលើលោក អៀង សារី ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ចូលនៅវេលាម៉ោង ៨:៥៥ព្រឹក-៩:១០ព្រឹក ឯកសារ E248.1។

[8] *សូមមើល* សេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តីលើលោក អៀង សារី ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ ចូលនៅវេលាម៉ោង ១០:៣៦ព្រឹក-១០:៣៩ព្រឹក ឯកសារ E248/1.1។

[9] ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/148.1 ទំព័រ ៦។

6. អង្គជំនុំជម្រះសាលាដំបូង គួរតែចាត់តាំងក្រុមវេជ្ជប ណ្ឌិតដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ឲ្យពិនិត្យសុខភាពរបស់លោក អៀង សារី ជារៀងរាល់ថ្ងៃ និងធ្វើការវាយតម្លៃ*ទៅលើបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងនា*ដូចជា៖

(ក) កម្រិតសមត្ថភាពរបស់លោក អៀង សារី ដើម្បីផ្តង់អារម្មណ៍ នៅពេលដែលគាត់អស់កម្លាំងខ្លាំង ឬវិលមុខ ឬនៅពេលដែលគាត់ឈឺចុកចាប់។

(ខ) ថាតើ លោក អៀង សារី អាចនៅចងចាំសក្ខីកម្មរបស់សាក្សីដែរ ឬយ៉ាងណា នៅពេលដែលគាត់អស់កម្លាំងខ្លាំង ឬវិលមុខ ឬនៅពេលដែលគាត់ឈឺចុកចាប់។

(គ) និងថាតើ លោក អៀង សារី អាចមានសមត្ថភាពពេញលេញ ដើម្បីតាមដានដំណើរការនីតិវិធីដែរ ឬយ៉ាងណា នៅពេលដែលគាត់អស់កម្លាំងខ្លាំង ឬវិលមុខ ឬនៅពេលដែលគាត់ឈឺចុកចាប់នោះ។

7. ក្នុងករណីមិនទាន់មានសេចក្តីសម្រេចទៅលើសំណើសុំនេះ ឬយ៉ាងហោចណាស់ មិនទាន់មានជម្រើសផ្សេងទេ ក្រុមមេធាវីការពារក្តីលោក អៀង សារី សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យក្រុមវេជ្ជបណ្ឌិតប្រចាំ អ.វ.ត.ក ធ្វើការតាមដាន និងពិនិត្យសុខភាពប្រចាំថ្ងៃឲ្យបានជាក់លាក់ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃទៅលើសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយដល់ក្រុមមេធាវីការពារក្តីរបស់គាត់។ មិនត្រូវអនុញ្ញាតឲ្យក្រុមវេជ្ជបណ្ឌិតគ្រាន់តែដាក់ជូននូវការកត់សម្គាល់ទូទៅដែលមិនច្បាស់លាស់ ឬកាន់តែធ្ងន់ជាងនេះទៅទៀតនោះ មិនត្រូវអនុញ្ញាតឲ្យក្រុមវេជ្ជបណ្ឌិតធ្វើការសន្និដ្ឋាន ដោយសំអាងទៅលើការខកខានរបស់លោក អៀង សារី ដែលមិនបានលើកឡើងពីបញ្ហាមួយចំនួន[10] ដូចជាថាតើគាត់អស់កម្លាំងខ្លាំង ឬមានការព្រួយបារម្ភអំពីការតាមដានដំណើរការនីតិវិធីដែរ ឬយ៉ាងណានោះទេ។ ក្រុមវេជ្ជបណ្ឌិតត្រូវតែមានគំនិតផ្តួចផ្តើមចាត់វិធានការជាមុន។ ត្រូវតែបង្គាប់ឲ្យក្រុមវេជ្ជបណ្ឌិតទាំងនេះ មិនត្រូវលើកឡើងអំពីការវិភាគទិន្នន័យសំខាន់ៗរបស់លោក អៀង សារី ប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវវាយការណ៍

[10] *សូមមើល* សេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តីលើលោក អៀង សារី ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E248/1.1 ចុះបញ្ជីនៅវេលាម៉ោង ៩:០២ នាទីព្រឹក-៩:០៧នាទីព្រឹក និងម៉ោង ៩:៣០ នាទីព្រឹក។

ជាប្រចាំ និងជាបន្តបន្ទាប់អំពីព័ត៌មានពាក់ព័ន្ធ ដែលពួកគាត់កត់សម្គាល់ឃើញផងដែរ ដូចជា ការត្អូញត្អែររបស់លោក អៀង សារី ការកត់សម្គាល់ឃើញរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី (ដែលនឹងធ្វើការតាមដានលើរូបគាត់) និងការកត់សម្គាល់ឃើញរបស់គិលានុបដ្ឋាយិកា និងអ្នកថែទាំរូបគាត់។ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើលោក អៀង សារី មានសមត្ថភាពតាមដានដំណើរការនីតិវិធីឲ្យបានពេញលេញដែរ ឬយ៉ាងណា (តាមរយៈការផ្តល់ព័ត៌មានសំខាន់ៗដើម្បីបង្ហាញអំពីសមត្ថភាពរបស់លោក អៀង សារីក្នុងការផ្តង់អារម្មណ៍ និងនឹកឃើញឡើងវិញនូវអ្វីដែលគាត់បានស្តាប់ឮ នៅពេលដែលគាត់អស់កម្លាំងខ្លាំង វិលមុខ ឬឈឺចុកចាប់)។ ក្រុមវេជ្ជបណ្ឌិត ត្រូវតែដាក់បញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួននូវព័ត៌មាន ដូចជា៖

(ក) ថាតើលោក អៀង សារី ភ្ញាក់ដឹងខ្លួនដែរ ឬយ៉ាងណា នៅពេលដែលវេជ្ជបណ្ឌិតណាម្នាក់ចូលទៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងថាតើគាត់មានសម្រាន្តលក់ដែរ ឬយ៉ាងណា នៅក្នុងអំឡុងថ្ងៃសវនាការនោះ (ហើយសម្រាន្តអស់រយៈពេលប៉ុន្មានដែរនោះ)។

(ខ) ថាតើលោក អៀង សារី វិលមុខញឹកញាប់ប៉ុណ្ណាដែរ និងថាតើការវិលមុខម្តងៗអស់រយៈពេលប៉ុន្មានដែរនោះ។

(គ) ថាតើលោក អៀង សារី អាចសម្រាន្តអស់រយៈពេលប៉ុន្មានដែរ ដោយមិនត្រូវការងាកចុះងាកឡើង ដោយសារតែភាពមិនងាយស្រួលនោះ។

(ឃ) ថាតើលោក អៀង សារី ស្ថិតក្នុងស្ថានភាពមួយ ដែលអាចក្រឡេកមើលអេក្រង់ទូរទស្សន៍បានញឹកញាប់ប៉ុណ្ណាដែរ ក្នុងមួយថ្ងៃៗនោះ។

(ង) និងថាតើលោក អៀង សារី អាចជម្រាបក្រុមវេជ្ជបណ្ឌិតទាំងនោះពីអ្វីដែលបាននឹងកំពុងតែកើតមានឡើងនៅក្នុងបន្ទប់សវនាការនៅថ្ងៃនោះ ឬនៅថ្ងៃមុនបានដែរ ឬយ៉ាងណានោះ។

ការរៀបរាប់ទាំងនេះ គឺមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ហើយគ្រាន់តែផ្តល់ជូនជាឧទាហរណ៍ពីប្រភេទព័ត៌មានដែលក្រុមវេជ្ជបណ្ឌិតប្រចាំនៅ អ.វ.ត.ក គួរតែដាក់បញ្ចូលក្នុងរបាយការណ៍របស់ខ្លួន។

**អាស្រ័យ**ទៅលើមូលហេតុទាំងអស់ ដូចបានលើកឡើងនៅក្នុងសំណើសុំនេះ ក្រុមមេធាវីការពារក្តីសុំស្នើបំពេញបន្ថែមទៅលើសំណើសុំរបស់ខ្លួន ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ដល់អ្នកជំនាញដែលមានគុណវុឌ្ឍិ ធ្វើការវាយតម្លៃប្រចាំថ្ងៃអំពីសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយដល់ក្រុមមេធាវីការពារក្តីរបស់គាត់ដោយឈរលើមូលដ្ឋានកំពុងតែបន្តមាន។ ក្រុមមេធាវីការពារក្តី សូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាបង្គាប់ឲ្យវេជ្ជបណ្ឌិតប្រចាំ អ.វ.ត.ក ធ្វើការស៊ើបអង្កេត និងធ្វើការកត់សម្គាល់ឲ្យបានច្បាស់លាស់ក្នុងមួយថ្ងៃៗ នៅទូទាំងថ្ងៃសវនាការ ដើម្បីវាយតម្លៃទៅលើសមត្ថភាពរបស់លោក អៀង សារី ក្នុងការជួយដល់ក្រុមមេធាវីការពារក្តីរបស់គាត់។

សូមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១២** ខែ **ធ្នូ** ឆ្នាំ **២០១២**។

សហមេធាវីការពារក្តីរបស់លោក អៀង សារី

________________ ________________

អាង ឧត្តម Michael G. KARNAVAS